**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា

## ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសបើកទិវាជាតិវេជ្ជសាស្ត្រ-ឱសថសាស្ត្រលើកទី ៩
## វិទ្យាស្ថានជាតិអប់រំ . ថ្ងៃ ១២ ខែ សីហា ឆ្នាំ ២០១០

- ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ
- លោក លោកស្រី សាស្ត្រាចារ្យ វេជ្ជបណ្ឌិត ឱសថការី ជាទីរាប់អាន
- និងក្មួយៗនិស្សិតជាទីមេត្រី

១- ថ្ងៃនេះ ជាថ្ងៃនក្ខត្តឫក្សប្រកបដោយក្តីសោមនស្សរីករាយជាអនេកប្បការ ដោយខ្ញុំមានកិត្តិយសចូលរួមជាមួយឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា នាឱកាសបើកទិវាជាតិវេជ្ជសាស្ត្រ-ឱសថសាស្ត្រ លើកទី ៩ នៅពេលនេះ ។ ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងការអបអរសាទរ និងកោតសរសើរយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំ និងក្រុមគ្រូពេទ្យកម្ពុជា សាស្ត្រាចារ្យ វេជ្ជបណ្ឌិត ឱសថការី ទាំងអស់ ទាំងនៅក្នុងប្រទេស និងប្រទេសបារាំង ដែលបានរៀបចំទិវាដ៏មានសារៈសំខាន់នាថ្ងៃនេះ ផ្តល់នូវអត្ថន័យដ៏ធំធេងក្នុងការលើកស្ទួយសុខភាពប្រជាពលរដ្ឋខ្មែរយើង និងពង្រឹងស្មារតីសាមគ្គីភាព សមត្ថភាព បច្ចេកទេស ក្នុងជួរគ្រូពេទ្យខ្មែរ ទាំង

ក្នុង និងក្រៅប្រទេស ដោយឈរលើស្មារតីគោរពគ្នា និងស្រឡាញ់គ្នាជាបងប្អូន ព្រមទាំងបង្កើតទំនាក់ទំនងល្អរវាងអ្នកមានវិជ្ជាជីវៈពេទ្យដូចគ្នា ។

២- ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវការកោតសសើរយ៉ាងស្មោះស្ម័គ្រ ចំពោះសមាគមទាំង ០៤ ដែលបានយកអស់កម្លាំងកាយ-ចិត្ត សហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីរៀបចំព្រឹត្តិការណ៍ ទិវាជាតិលើកទី ៩ នាថ្ងៃនេះឱ្យចេញជារូបរាង ។ ប្រធានបទទិវាជាតិលើកទី ៩ ក្នុងឆ្នាំនេះ ស្ថិតក្នុងពាក្យស្លោក " **សុខភាព ដើម្បីទាំងអស់គ្នា** " ដែលមានទិសដៅស្របគ្នានឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ឆ្នាំ២០១៥ នៃគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល ។ ខ្ញុំមានចំណាប់អារម្មណ៍ថា ប្រធានបទទាំង ១៤ ដែលនឹងត្រូវលើកឡើងនៅក្នុងការពិភាក្សា នៃទិវាជាតិវេជ្ជសាស្ត្រ-ឱសថសាស្ត្រ លើកទី៩ គឺពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់ដល់ក្រុមគ្រូពេទ្យកម្ពុជា ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក និងចែករំលែកចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗដែលទាក់ទងនឹងវិស័យវេជ្ជសាស្ត្រ និងឱសថសាស្ត្រ ។

៣- សមាជិក-សមាជិកានៃអង្គវេទិកាទាំងអស់បានជ្រាបស្រាប់ហើយថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានផ្តល់អាទិភាពខ្ពស់ដល់វិស័យសុខាភិបាល ។ ក្នុងទិសដៅយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល នីតិកាលទី ៤ នៃរដ្ឋសភា បានបញ្ជាក់ច្បាស់ថា : រាជរដ្ឋាភិបាលបានចាត់ទុកសុខភាពប្រជាពលរដ្ឋ គឺជាកត្តាដ៏ចម្បងសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងវឌ្ឍន៍ភាពសង្គម និងសេដ្ឋកិច្ចប្រកបដោយចិរភាព ហើយរាជរដ្ឋាភិបាលបានលើកស្ទួយសុខុមាលភាពប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រ ស្ត្រី និងកុមារ ។ ឈរលើស្មារតីនេះ យើងត្រូវពង្រឹងគុណភាពសេវាសុខភិបាល ក្នុងនោះត្រូវផ្អែកលើកត្តាសំខាន់ៗមួយចំនួន ដូចជា ត្រូវមានការបណ្តុះបណ្តាលជាមូលដ្ឋាន ដែលមានកម្មវិធីកម្រិតស្តង់ដារអន្តរជាតិ មានការសិក្សាស្រាវជ្រាវ ពង្រីកមន្ត្រីសុខាភិបាលប្រកបដោយគុណភាពខ្ពស់ឱ្យទៅដល់មូលដ្ឋានជនបទ មាននិរន្តរ៍ភាពនៃការបណ្តុះបណ្តាលបន្តមានការគោរពក្រឹត្យក្រម និងសីលធម៌វិជ្ជាជីវៈខ្ពស់ មានឱសថប្រកបដោយគុណភាពគ្រប់គ្រាន់ ។ល។ ទាំងអស់នេះ គឺជាកត្តាមិនអាចខ្វះបានក្នុងការធានានូវធនធានមនុស្ស ដែលមានសមត្ថភាព និងគុណភាពខ្ពស់ ។

៤- យើងមានមោទនភាពធំធេងណាស់ ក្នុងការកសាងមូលដ្ឋានសុខាភិបាល ដែលមានបុគ្គលិកពេទ្យរហូតដល់ភូមិ-ឃុំ និងមានការចូលរួមយ៉ាងសកម្មពីសហគមន៍ សប្បុរសជននៅគ្រប់មជ្ឈដ្ឋាន ទាំងវិស័យសាធារណៈ

និងវិស័យឯកជន ជាពិសេស ការឧបត្ថម្ភពីបណ្តាប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍនានាជាដើម ។ អាទិភាពចម្បងរបស់សុខាភិបាល គឺការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ដោយយើងបានពង្រាយឆ្មបនៅគ្រប់មណ្ឌលសុខភាព មិនតែប៉ុណ្ណោះយើងថែមទាំងអភិវឌ្ឍជាបន្តបន្ទាប់ ទាំងគុណភាព និងបរិមាណនៃវិស័យសុខាភិបាល ។ យើងមានសុឆន្ទៈ និងមានមោទនភាពខ្លាំងណាស់ ក្នុងការសម្រេចឱ្យបាននូវមហិច្ឆិតានេះ ដោយយើងមានគោលនយោបាយត្រឹមត្រូវ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំដ៏ឈ្លាសវៃ និងមានបទពិសោធន៍ដ៏សំបូរបែប ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ទាំងវិស័យអាណាចក្រ និងវិស័យពុទ្ធចក្រ ពិសេសគឺការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដែលបានបង្កបង្កើតឱ្យមានភាពកាន់តែជិតគ្នា រវាងទីក្រុង និងជនបទ ។ នេះជាសច្ចះធម៌ក្នុងប្រវត្តិសាស្ត្ររបស់យើង ហើយក៏គ្មានអ្នកណាម្នាក់ហ៊ានបដិសេធថា មិនបានទទួលនូវមនុញ្ញផលនៃការអភិវឌ្ឍនេះដែរ ។

៥- ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យវេជ្ជបណ្ឌិត ឱសថការី និងក្មួយៗនិស្សិតសុខាភិបាលនៅភ្នំពេញ និងមកពីប្រទេសបារាំង ដែលបានចូលរួមក្នុងអង្គសន្និសីទវិទ្យាសាស្ត្រនេះ ដើម្បីធ្វើឱ្យមុខវិជ្ជាឯកទេសវេជ្ជសាស្ត្រ ឱសថសាស្ត្រ កាន់តែលើកកម្ពស់ខ្លាំងក្លាថែមទៀត ។ ទោះយ៉ាងណាក្តី ដើម្បីរត់ឱ្យទាន់ការវិវឌ្ឍន៍សកលលោក យើងត្រូវការអ្នកបច្ចេកទេសចំណានៗ និងឧបករណ៍ទំនើបៗ ដើម្បីស្រោចស្រង់ជីវិតបងប្អូនជនរួមជាតិរបស់យើង ឱ្យរួចផុតពីជម្ងឺ និងសេចក្តីស្លាប់ ។ ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរសមាគមគ្រូពេទ្យ និងឱសថការីយើង ទាំងនៅក្នុងស្រុក និងនៅប្រទេសបារាំង ដែលបានរៀបចំទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ នេះឡើងក្នុងគោលបំណងយ៉ាងឧត្តុង្គឧត្តម គឺពង្រីកទំនាក់ទំនង ពង្រឹងចំណងមិត្តភាព-សាមគ្គីភាព រវាងអ្នកមានវិជ្ជាជីវៈដូចគ្នា ទាំងក្នុង និងក្រៅប្រទេស និងបង្កើនចំណេះដឹងខាងបច្ចេកទេសជំនាញវេជ្ជសាស្ត្រ-ឱសថសាស្ត្រ រៀនសូត្រ-ដកពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីរួមចំណែកលើកកម្ពស់សេវាសុខាភិបាល ។ ខ្ញុំសូមឱ្យស្មារតី និងវប្បធម៌បែបនេះ មានជានិច្ចនិរន្តរ៍តទៅមុខទៀតក្នុងវិស័យសុខាភិបាល ។ រាជរដ្ឋាភិបាលកម្ពុជា សូមវាយតម្លៃខ្ពស់ នូវការរួមចំណែករបស់បណ្តាអង្គការដៃគូអភិវឌ្ឍ និងសប្បុរសជននានា ក្នុងការអភិវឌ្ឍហេរដ្ឋារចនាសម្ព័ន្ធសុខាភិបាល ដែលជាសរសរគ្រឹះមួយដ៏សំខាន់ក្នុងការជួយជំរុញល្បឿនកិច្ចអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

៦- អ្វីដែលយើងទាំងអស់គ្នា ពិសេសអង្គសន្និសិទជាតិ បានយកចិត្តទុកដាក់នោះគឺ ការបង្កើត និងពង្រឹងនូវធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ ដើម្បីផ្តល់សេវាប្រកបដោយគុណភាពជូនប្រជាជន និងធ្វើឱ្យប្រជាជនមានជំនឿជឿទុកចិត្តមកលើសេវាសុខាភិបាល ។ ខ្ញុំសូមគាំទ្រកម្មវិធីបណ្តុះបណ្តាលបន្តនេះ ដើម្បីធ្វើឱ្យគ្រូពេទ្យ និងឱសថការីយើង ដែលទើបចេញពីមហាវិទ្យាល័យក្តី ដែលកំពុងបំពេញការងារក្តី អាចបង្កើនចំណេះដឹង និងរត់ឱ្យទាន់ការវិវឌ្ឍន៍ នៃបច្ចេកវិទ្យាសកលលោក ។ ទន្ទឹមនឹងនេះ ខ្ញុំសូមឱ្យសមាគមទាំង ៤ ពិនិត្យលទ្ធភាពក្នុងការបន្ថយទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រនេះ ឱ្យបានវែង និងប្រកបដោយនិរន្តរភាព ។

## ឯកឧត្តម លោកជំទាវ លោក_លោកស្រី ភ្ញៀវកិត្តិយស ជាទីមេត្រី !

៧- រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បាន និងកំពុងខិតខំធ្វើអ្វីៗសព្វយ៉ាងទាំងអស់ សំរាប់អនាគតថ្កុំថ្កើង នៃកូនចៅជំនាន់ក្រោយរបស់ជាតិខ្មែរយើង ។ ខ្ញុំសូមឆ្លៀតឱកាសដ៏មហោឡារិកនេះ ជំរាបថា នយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺជាមូលដ្ឋានគ្រឹះ និងជាស្នូលនៃការធានាឱ្យមានស្ថេរភាពនយោបាយ និងការអភិវឌ្ឍន៍ជាតិលើគ្រប់វិស័យ ។ ស្របតាមបាវចនានៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ក្នុងនិតិកាលទី ៤ នៃរដ្ឋសភា គឺ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ។

៨- រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង លើវិស័យអប់រំ បណ្តុះបណ្តាលមន្ត្រីរាជការឱ្យមានអត្តចរិត និងសមត្ថភាព ស្របទៅនឹងសេចក្តីត្រូវការរបស់ប្រទេសជាតិ ។ លក្ខណៈពិសេសនៃមន្ត្រីរាជការទាំងនោះ គឺត្រូវមានឥរិយាបថអព្យាក្រិត្យ មិនប្រកាន់បក្សពួក បុគ្គលិកមន្ត្រីរាជការត្រូវមានកិត្តិយសក្នុងការបំរើជាតិ និងប្រជាជនយ៉ាងស័ក្តិសមបំផុត ។ ឆ្លើយតបទៅនឹងអាទិភាពនៃការបណ្តុះបណ្តាលធនធានមនុស្ស និងកាយវិការយកចិត្តទុកដាក់ដល់សុខភាពប្រជាជន រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនថវិកាជាតិជារៀងរាល់ឆ្នាំ ដើម្បីបំរើវិស័យសុខាភិបាល ។ សកម្មភាពរបស់សមាគមគ្រូពេទ្យ ឱសថការីទាំង ៤ និង ទិវាវេជ្ជសាស្ត្រ-ឱសសាស្ត្រ នាថ្ងៃនេះ គឺជាចលនារួមគ្នាលើកស្ទួយវិស័យសុខាភិបាល នៅកម្ពុជា ឱ្យទៅជាវិស័យសុខាភិបាលមួយដែលមានប្រសិទ្ធិភាពខ្ពស់ និងមានទំនុកចិត្តពីប្រជាជន ។

៩- មុននឹងបញ្ចប់សុន្ទរកថា ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមអំពាវនាវដល់អង្គការជាតិ និងអន្តរជាតិ ព្រមទាំងសប្បុរសជននានា សូម

មេត្តាបន្តជួយឧបត្ថម្ភគាំទ្រ ជាសម្ភារៈក្តី ជាស្មារតីក្តី ជូនដល់គណៈកម្មាធិការរៀបចំទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រតទៅអនាគតទៀត សម្រាប់គោលដៅរួមទាំងគ្នា គឺសហការដើម្បីវឌ្ឍនភាពនៃវិស័យសុខាភិបាលកម្ពុជា ។ ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជ័យបវរសួស្តី ជូនឯកឧត្តម លោកជំទាវ លោក-លោកស្រី ប្អូនៗនិស្សិត សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និង សូមប្រកាសបើកនូវទិវាជាតិវេជ្ជសាស្ត្រ-ឱសថសាស្ត្រ លើកទី ៩ ចាប់ពីពេលនេះតទៅ ។

***សូមអរគុណ !***